ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការក្រុងភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៤៥៩ ចុះថ្ងៃទី ៣០
ខែ មីនា ឆ្នាំ ២០០០
ជំនុំជំរះលេខ ៤៤៧ ចុះថ្ងៃទី ១៣
ខែ កក្កដា ឆ្នាំ ២០០០
សាលក្រម
លេខ ៤៤ "គ" ចុះថ្ងៃទី ២០
ខែ កញ្ញា ឆ្នាំ ២០០០

សាលក្រមនេះចូលជាស្ថាពរ ចាប់ពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០០ តទៅ
ដោយគ្មានភាគីណាមួយប្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលកំណត់ច្បាប់ ។
ភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០០
ក្រឡាបញ្ជី
[redacted]

## គាននាមប្រជារាស្ត្រខ្មែរ
## តុលាការក្រុងភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣។

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះតុលាការក្រុងភ្នំពេញ នាថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០០ ដែលមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការក្រុងភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងភ្នំពេញ

**អ្នកការពារអោយជនជាប់ចោទ**

លោក [redacted] សោភា

**ដើម្បីជំនុំជំរះ**

សំណុំរឿងព្រហ្មទណ្ឌលេខ : ៤៥៩ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០០ ដែលមានជនជាប់ចោទឈ្មោះ :

១-ម សម ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិតាហ៊ុល ឃុំទី ២ ខេត្តសៀមរាប សាសនាព្រះពុទ្ធ ។ ទីលំនៅសព្វថ្ងៃ មិនពិតប្រាកដ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន ក្រុងភ្នំពេញ របររកស៊ី មិនពិតប្រាកដ ។ ប្រពន្ធឈ្មោះ ទ ច កូនគ្មាន ឪពុកឈ្មោះ ម ជន (រ) ម្តាយឈ្មោះ ស រ (រ) ទោសពីមុន *គ្មាន* ឃុំខ្លួនថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០០ ។

២-ស ល ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃកផ្លាវ ឃុំកំពង់កុង ស្រុកស្អាង ខេត្តកណ្តាល សាសនាព្រះពុទ្ធ ទីលំនៅភូមិព្រៃកផ្លាវ ឃុំកំពង់កុង ស្រុកស្អាង ខេត្តកណ្តាល របររកស៊ី កម្មករយីត្រី គីឡូម៉ែត្រលេខ ៩ នៅលីវ ឪពុកឈ្មោះ ៩ ស (រ) ម្តាយឈ្មោះ គ ខ (រ) ទោសពីមុន *គ្មាន* ឃុំខ្លួនថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០ ។

៣-ស ឌ ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃកផ្លាវ ឃុំកំពង់កុង ស្រុកស្អាង ខេត្តកណ្តាល សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិព្រៃកផ្លាវ ឃុំកំពង់កុង ស្រុកស្អាង ខេត្តកណ្តាល របររកស៊ីលក់គុយទាវ នៅលីវ ឪពុកឈ្មោះ ស ៩ (រ)

ម្ដាយឈ្មោះ ឌ ឃ (រ) ទោសពី មុនគ្មានឃុំខ្លួនថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០ ។

៤-ឈ ឆ ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកំពង់កុង ឃុំកំពង់កុង ស្រុកស្អាង ខេត្តកណ្ដាល សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់កុង ឃុំកំពង់កុង ស្រុកស្អាង ខេត្តកណ្ដាល របររកស៊ី ធ្វើស្រែចំការ ប្រពន្ធឈ្មោះ ចា កូនគ្មាន ។ ទោសពីមុន *គ្មាន* ឃុំខ្លួនថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០ ។

ជាប់ចោទពីបទ "ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនរងគ្រោះឈ្មោះ យ ឃ ភេទប្រុស អាយុ ៤២ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិព្រែកតាប្រាក់ ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្ដាល ។

**<u>ឯរឿងហេតុមានដូចតទៅ</u> :**

តាមរបាយការណ៍សរុបករណីវាយប្លន់ម៉ូតូឌុប ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០ របស់នគរបាលប៉ុស្តិ៍រដ្ឋបាល ទំនប់ទឹក បញ្ជាក់ថា : កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០ វេលាម៉ោង ០៣ និង ៣០នាទីជិតភ្លឺ មានករណីវាយប្លន់ម៉ូតូឌុបម៉ាកសាន់យ៉ាន់ ពណ៌ខៀវ នៅចំណុចផ្លូវលេខ ៤៣០ បង្កឡើងដោយជនល្មើស ០៤នាក់ ស្លៀកពាក់ស៊ីវិល ដោយ ០២នាក់ បានហៅម៉ូតូឌុបពីទំនប់ទួលគោក មកកន្លែងកើតហេតុ ។ លុះមកដល់ជនល្មើស ០២នាក់ទៀត ដែលដេកនៅតូបក្បែរនោះ ក៏ចេញមកព្រួតគ្នាវាយប្លន់ម៉ូតូជនរងគ្រោះ រួចយកម៉ូតូជនរងគ្រោះគេចខ្លួនតែម្ដង ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៤១២៨ ត.ព្រ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០០ ។

**<u>នាពេលសចនាការ</u>**

ជនជាប់ចោទឈ្មោះ **ស ឧ** ឆ្លើយថា : នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០ វេលាម៉ោង ៣:០០ជិតភ្លឺ ខ្លួន ០២នាក់ **ស ល** បានជិះម៉ូតូឌុបពីទំនប់ទួលគោក ទៅក្រោយបេនឡានអូតែលថៃប៉ុនរ៉ុង ពេលទៅដល់ខ្លួនអត់មានលុយអោយថ្លៃម៉ូតូ មាននាឡិកាអត់កញ្ចក់ ០១ អោយម្ចាស់ម៉ូតូ តែគាត់ពុំយក ពេលនោះឈ្មោះ **ឈ ឆ** អោយខ្លួនវាយតាម៉ូតូឌុបទៅ ពេលនោះកើតមានទំនាស់គ្នា ពួកខ្លួនមានគ្នា ០៤នាក់ បាននាំគ្នាព្រួតវាយលើតាម៉ូតូឌុប ។ តាម៉ូតូឌុបបានស្រែកថាចោរៗ ដោយខឹងតានោះស្រែកថាចោរៗ ខ្លួន និង **ស ល** បានយកម៉ូតូរបស់តាម្ចាស់ម៉ូតូឌុបនោះជិះទៅហើយយកទៅលក់នៅកោះធំអោយពួកយួន បានតម្លៃ ១០០ដុល្លាចែកគ្នា ០២នាក់ **ស ល** បាន ៤០ដុល្លា ម្នាក់ ២០ដុល្លាធ្វើម៉ូតូអស់ ។

-ជនជាប់ចោទឈ្មោះ **ស ល** ឆ្លើយថា ខ្លួនគ្មានអ្វីឆ្លើយបន្ថែមទៀតទេ គឺដូចគ្នានឹងចម្លើយឈ្មោះ **ស ឧ** ដែរ ។ ពេលចែកលុយគ្នាហើយត្រឡប់មកវិញ ខ្លួនបានអោយលុយឈ្មោះ **ឈ ឆ** ១០.០០០រៀល ។

-ជនជាប់ចោទឈ្មោះ **ឈ ឆ** ឆ្លើយថា : នៅថ្ងៃកើតហេតុ ខ្លួននៅជាមួយឈ្មោះ **ស សម** នៅការ៉ាសឡានថៃប៉ុនរ៉ុង ពេលនោះឈ្មោះ **ឧ** និង ឈ្មោះ **ល** បានជិះម៉ូតូឌុបមកដល់ពេលម៉ូតូឈប់ ខ្លួនឮពួកវាឈ្លោះជាមួយតាម៉ូតូឌុប ហើយតាម៉ូតូឌុបស្រែកថាចោរៗ ខ្លួន និង ឈ្មោះ **ស សម** បានចេញទៅជួយចាប់ និង វាយតាម៉ូតូឌុប ពេលតាម៉ូតូឌុបដួល ឈ្មោះ **ស ឧ** និង **ស ល** បានយកម៉ូតូតាម៉ូតូឌុបជិះចេញទៅ ។ ឈ្មោះ **ស ល** អោយលុយខ្លួន ១០.០០០ រៀល ។ ខ្លួនស្គាល់គ្នា ដោយនៅស្រុកជាមួយគ្នា ។

-ជនជាប់ចោទឈ្មោះ **ម សម** ឆ្លើយថា : នៅថ្ងៃកើតហេតុ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០០ ខ្លួននៅអង្គុយលេងជាមួយ **ឈ ឆ** នៅការ៉ាសឡានថៃប៉ុនរ៉ុង មានម៉ូតូឌុប ១ បានឌុបជន ០២នាក់ ពេលនោះខ្លួនពុំស្គាល់ជននោះ

CamScanner

ទេ ។ ជននោះថាមកពីទូលគោក សុំកន្លែងដេក ពេលគេចុះហើយ ម៉ូតូឌុបពុំព្រមទៅខ្លួនសួរគាត់ថាម៉ាំយកលុយ ។ ក្រោយពេលប្រកែកគ្នា មានការវាយតប់ខ្លួនចូលទៅជួយចាប់ត្រៀកម្ចាស់ម៉ូតូឌុប ។ ខ្លួនពុំបានដឹងថា គេយកម៉ូតូតាម៉ូតូឌុបទេ ។ ខ្លួនពុំបានទទួលលុយទេ ។

-ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះឈ្មោះ **ឃ ឃ** ដែលអវត្តមាន ។

-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា ផ្អែកតាមចម្លើយជនរងគ្រោះ តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងវត្ថុតាងបញ្ជាក់ច្បាស់ថា ជនជាប់ចោទពិតជាប្រើអំពើហឹង្សារួមគ្នា យកម៉ូតូរបស់ជនរងគ្រោះ នោះគឺជាអំពើប្លន់ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សូមតម្កល់ការចោទប្រកាន់ដដែល សូមតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវីជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា : ឆ្លងតាមសវនាការនេះ ខ្លួនយល់ឃើញថា រឿងហេតុកើតឡើងកន្លងមកនេះ តាមរយៈអង្គហេតុបណ្តាលមកពីឈ្មោះ **ស ឌ** និង **ស ល** មិនអោយលុយថ្លៃម៉ូតូឌុបអោយនាឡិកាម្ចាស់ម៉ូតូមិនយក ក៏កើតទៅជាទំនាស់វាយគ្នា ។ ម្ចាស់ម៉ូតូស្រែកថាចោរ ពេលនោះបទប្លន់ពុំទាន់កើតឡើងទេ ។ ដោយសារខឹងស្រែកថាចោរ ទើបជនជាប់ចោទយកម៉ូតូទៅតែម្តង ។ លក់បាន ១០០$ចែកគ្នាតែ ០២នាក់ ឈ្មោះ **ស ល** និង **ស ឌ** ។ចំណែក **ឈ ឆ** និង **ម សម** ពុំបានដឹងថាឈ្មោះ **ស ល** និង **ស ឌ** យកម៉ូតូទេ គឺគ្រាន់តែបានចូលវាយម្ចាស់ម៉ូតូតែប៉ុណ្ណោះ ។ សកម្មភាពកើតឡើងដោយចៃដន្យកើតឡើងអត់ការព្រៀងទុក ដូច្នេះឈ្មោះ **ឈ ឆ** និង **ស សម** គ្រាន់តែបានប្រព្រឹត្តបទបង្ករបួសស្នាមតែប៉ុណ្ណោះ ពីព្រោះពុំបានទទួលផលអ្វីទេ ។

ការប្រព្រឹត្តរបស់ជនជាប់ចោទ ខ្វះការពិចារណា ដោយជីវភាពក្រលំបាក មានចំណេះដឹងតិច ទើបប្រព្រឹត្តលើកទី ១ គេបានសារភាពហ៊ានទទួលខុសត្រូវចំពោះអំពើរបស់គេដែលបានប្រព្រឹត្ត ។ សូមតុលាការបន្ធូរបន្ថយទោសតាមមាត្រា ៦៨ និង មាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ សូមតុលាការកែប្រែបទល្មើសរបស់ឈ្មោះ **ឈ ឆ** និង **ម សម** មកជាបទបង្ករបួសស្នាម ។

-ជនជាប់ចោទនិយាយសំដីចុងក្រោយថា : សុំអោយតុលាការបន្ធូរបន្ថយទោសអោយខ្លួន ដើម្បីអោយខ្លួនបានកែប្រែខ្លួន ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានពិនិត្យចម្លើយជនរងគ្រោះ

-ក្រោយពីបានពិនិត្យឯកសារសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

## តុលាការក្រុងភ្នំពេញ
## យល់ឃើញថា

-មានបន្ទុកគ្រប់គ្រាន់បញ្ជាក់ថា **ស ឌ** ភេទប្រុស អាយុ ២០ឆ្នាំ. **ស ល** ភេទប្រុស អាយុ ២២ឆ្នាំ. **ឈ ឆ** ភេទប្រុស អាយុ ២០ឆ្នាំ និង ឈ្មោះ **ម សម** ភេទប្រុស អាយុ ២៤ឆ្នាំ ពិតជាបានប្រព្រឹត្តបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តកាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០ នៅក្រុងភ្នំពេញ ប្រាកដមែន ។

បទល្មើសព្រហ្មទណ្ឌមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

CS CamScanner

-សំណូមពររបស់ជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណី មានលក្ខណៈសមស្របតាមច្បាប់ ។

-ជនជាប់ចោទបានសារភាពដោយស្មោះត្រង់នៅចំពោះមុខសវនាការ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវី មានលក្ខណៈគួរតុលាការពិចារណា ។

**ហេតុដូច្នេះតុលាការក្រុងភ្នំពេញ**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសឈ្មោះ **ស ឆ** ភេទប្រុស អាយុ ២០ឆ្នាំ, **ស ល** ភេទប្រុស អាយុ ២២ឆ្នាំ និង ឈ្មោះ **ឈ ឆ** ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣ឆ្នាំ (បីឆ្នាំ) គិតពីថ្ងៃឃុំខ្លួន "ថ្ងៃឃុំខ្លួនថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០" ដាក់ពន្ធនាគារ **ម សម** ភេទប្រុស អាយុ ២៤ឆ្នាំ ចំនួន ០៣ឆ្នាំ (បីឆ្នាំ) គិតពីថ្ងៃឃុំខ្លួន "ថ្ងៃឃុំខ្លួនថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០០" ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០ តាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-អោយឈ្មោះ **ស ឆ**, **ស ល**, **ឈ ឆ** និង ឈ្មោះ **ម សម** រួមគ្នាសងថ្លៃម៉ូតូចំនួន ៥០០ (ប្រាំរយដុល្លាអាមេរិក) និងជម្ងឺចិត្តចំនួន ២០០$ (ពីររយដុល្លាអាមេរិក) អោយទៅឈ្មោះ **យ យ**។ សំណូមពរសុំទាមទារជម្ងឺចិត្ត លើសពីនេះត្រូវបដិសេធចោល ។

ករណីរឹងទទឹងពុំព្រមសង ត្រូវដាក់គុកបង្ខំដល់រូបកាយឈ្មោះ **ស ឆ**.**ស ល**.**ឈ ឆ** និង ឈ្មោះ **ម សម** និង រឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងចាទាសងតាមច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ សំរេចបើកផ្លូវឧទ្ធរណ៍ រយៈពេល ០២ខែគិតពីថ្ងៃនេះតទៅ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។**

*ភ្នំពេញ.ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៤*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]

CamScanner